**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្តាល**

**សំណុំរឿងព្រហ្មទណ្ឌ**

លេខ៖ ៣៩៦ អ.ក

ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២១

ជំនុំជម្រះលេខ៖១០១៤ជរ

ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២១

សាលក្រមលេខ:១០២(ប)

ចុះថ្ងៃទី២៥ខែសីហា ឆ្នាំ២០២១

# តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តកណ្តាល

បានបើកសវនាការជាសាធារណៈនៅសាលាដំបូងខេត្តកណ្តាល

**នៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២១ ដោយមានសមាសភាព៖**

## ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្តាល **ជាប្រធានក្រុមប្រឹក្សា**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្តាល **ជាចៅក្រមប្រឹក្សា**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្តាល **ជាចៅក្រមប្រឹក្សា**

## តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកណ្តាល

## ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្តាល

## ដើម្បីជំនុំជម្រះ

**លើសំណុំរឿងព្រហ្មទណ្ឌលេខ:** ៣៩៦ អ.ក ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២១ **ដែលមាន៖**

-ឈ្មោះ [redacted] ចំរើន ហៅតុន ភេទប្រុស អាយុ១៧ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ សាសនាព្រះពុទ្ធ មានទីកន្លែងកំណើត និងទីលំនៅមុនពេលឃាត់ខ្លួននៅ [redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] រ៉ាធនី (ស្លាប់) ម្តាយឈ្មោះ [redacted] សារ៉េត (រស់) នៅលើវ ទោសពីមុនធ្លាប់ជាប់ពន្ធនាគារ២ឆ្នាំ ។

**(ឃាត់ខ្លួនថ្ងៃទី០៩ ខែមីនាឆ្នាំ២០២១ ឃុំខ្លួនតាមដីកាលេខ៖៨១៤ថ្ងៃទី០៩ ខែមីនាឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាល)។**

ជាប់ចោទពីបទ៖ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិធម្មត្រ័យ ឃុំផ្សារដែក ស្រុកពញាឮ ខេត្តកណ្តាល កាលពីថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌ៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-លោក [redacted] មេធាវីការពារសិទ្ធិឱ្យជាប់ចោទ។

-បានឃើញ របាយការណ៍លេខ៖០០៩ រ.ប.កចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២១ របស់ស្នងការដ្ឋាននគរបាលខេត្តកណ្តាលនៃអធិការដ្ឋាននគរបាលស្រុកពញាឮ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ៖៩៥៩ដក.សព/២១ចុះថ្ងៃទី០៧ ខែ ឧសភា ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្តាល។

-បានឃើញ ដីកាដំណោះស្រាយលេខ៖១០៥៧ ដក.ដស ចុះថ្ងៃទី១៣ខែឧសភា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្តាល។



Scanned with CamScanner

## អង្គហេតុនៃរឿងមានដូចតទៅ

នៅពីថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២១ វេលាម៉ោង ១៩និង៥០នាទី កម្លាំងនគរបាលប៉ុស្តិ៍រដ្ឋបាលឃុំផ្សារដែរ បានទៅយាមគោលដៅចត្តាឡីស័កនៅសាលាទេពប្រណម្យស្ថិតនៅភូមិធម្មត្រ័យ ឃុំផ្សារដែក ស្រុកពញាឮ ខេត្តកណ្តាល។ ពេលទៅដល់ចំណុចផ្លូវចូលភ្នំព្រះរាជទ្រព្យ បានឃើញឈ្មោះ[redacted]ចំរើន ហៅតុន ភេទប្រុស អាយុ១៧ឆ្នាំ កំពុងធ្វើសកម្មភាពជួញដូរថ្នាំញៀន ភ្លាមនោះកម្លាំងសមត្ថកិច្ចនគរបាលប៉ុស្តិ៍ក៏បានធ្វើការឃាត់ខ្លួនជនសង្ស័យឈ្មោ[redacted] ចំរើន ហៅតុន និងឆែកឆេររកឃើញថ្នាំញៀនចំនួន០១កញ្ចប់តូចធ្វើការដកហូត ចំណែកជនសង្ស័យផ្សេងទៀតបានរត់គេចខ្លួនគ្មានសាវតាជាតិគ្រប់គ្រាន់ឡើយ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ[redacted] ចំរើន ហៅ តុង បានឆ្លើយថា៖ កាលពីថ្ងៃកើតហេតុឈ្មោះ យ៉ា បានទូរស័ព្ទមកឱ្យខ្លួនទិញគ្រឿងញៀន១កញ្ចប់តម្លៃ៥ម៉ឺនប្រភេទម៉ាទឹកកកឱ្យខ្លួនជិះម៉ូតូម៉ាកសង់C-125 ពណ៌ខ្មៅពាក់ស្លាកលេខភ្នំពេញ1Q-1804 របស់ខ្លួនជាមួយឈ្មោះ យ៉ា យកគ្រឿងញៀនឱ្យគេនៅភូមិធ្មត្រ័យ ពេលមកដល់មិនទាន់បានប្រគល់គ្រឿងញៀនឱ្យគេផង ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង ហើយឈ្មោះ យ៉ា បានរត់គេចខ្លួន។ ខ្លួនទិញគ្រឿងញៀនពីឈ្មោះ សែន, ខ្លួនធ្លាប់លក់គ្រឿងញៀនបាន២ដង, ខ្លួនចេះប្រើប្រាស់គ្រឿងញៀន, ខ្លួនធ្លាប់តុលាការផ្តន្ទាទោសពីបទជួញដូរគ្រឿងញៀនជាប់ពន្ធនាគាររយៈពេល៣ឆ្នាំ។

-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ៖ ក្រោយពីបានស្តាប់ចម្លើយសារភាពរបស់ជនជាប់ចោទ ឃើញថា ជនជាប់ចោទពិតជាបានជួញដូរគ្រឿងញៀន។ រីឯបក្សពួកបានរត់គេចខ្លួន គ្មានសាវតារជាតិ ហើយត្រូវបានចៅក្រមស៊ើបសួរលើកលែងចោទប្រកាន់រួចហើយ ,ជនជាប់ចោទជាអនីតិជនពិតមែន តែត្រូវទទួលខុសត្រូវបទព្រហ្មទណ្ឌចំពោះមុខច្បាប់ តំណាងអយ្យការស្នើសុំរតម្កល់បទចោទប្រកាន់ទុកដដែល ជូនតុលាការសម្រេចតាមច្បាប់។

-សេចក្តីសន្និដ្ឋានមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ៖ ជនជាប់ចោទបានជួញដូរគ្រឿងញៀនដោយសារបក្សពួកបញ្ឆោឱ្យលក់ សំណូមពរឱ្យតុលាការលើកលែងបទចោទប្រកាន់។

+សម្តីចុងក្រោយរបស់ជនជាប់ចោទ៖ ស្នើសុំតុលាការបន្ធូរបន្ថយទោស។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យ ឯកសារ ភស្តុតាង

-ក្រោយពីបាន ពិចារណា ពិភាក្សាក្រុមប្រឹក្សាត្រឹមត្រូវតាមច្បាប់ហើយ។

## សំអាងហេតុ

១.តុលាកាទទួលសំណុំរឿងព្រហ្មទណ្ឌ ពីចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្តាល ដែលមានជនជាប់ចោទឈ្មោះ[redacted] **ចំរើន ហៅតុន** ភេទប្រុស អាយុ ១៧ឆ្នាំ ពីបទ៖ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** តាម



Scanned with CamScanner

ដីកាដំណោះស្រាយលេខ: ១០៥៧ ដក.ដស ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២១ តុលាការធ្វើការជំនុំជម្រះលើជនជាប់ចោទយោងតាមមាត្រា ២៨៩ ,មាត្រា ២៩១ និងមាត្រា ៣៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២.ផ្អែកតាមចម្លើយរបស់ជនជាប់ចោទ និងភស្តុតាង បញ្ជាក់ថា: ជនជាប់ចោទឈ្មោះ [redacted] ចំរើន ហៅតុង ពិតជាបានធ្វើសកម្មភាពជិះម៉ូតូយកថ្នាំញៀនចំនួន ០១កញ្ចប់ តំលៃ ៥ម៉ឺនរៀលទៅលក់ឱ្យគេប្រាកដមែន។ អំពើរបស់ជនជាប់ចោទ គឺជាអង្គហេតុត្រូវនឹងធាតុផ្សំបទល្មើស **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ដែលមានចែងក្នុងបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៤ **នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន**។

៣.ជនជាប់ចោទឈ្មោះ [redacted] ចំរើន ហៅ តុង មានសតិសម្បជញ្ញៈ និងសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវបទព្រហ្មទណ្ឌនូវទង្វើរបស់ខ្លួន។

៤.សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការបានចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] ចំរើន ហៅ តុង ពីបទ៖ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ហើយសុំតម្កល់បទចោទប្រកាន់នេះទុកដដែលនោះ គឺមានលក្ខណៈត្រឹមត្រូវតាមច្បាប់។

៥.សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ៖ ស្នើសុំលើកបទចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] ចំរើន មិនត្រឹមត្រូវទេ។

៦.តាមកំណត់ហេតុធ្វើតេស្តបឋម និងវេចខ្ចប់វត្ថុតាង ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២១ របស់ស្នងការដ្ឋាននគរបាលខេត្តកណ្តាល ផ្នែកនគរបាលប្រឆាំងគ្រឿងញៀន ឃើញមាន ម្សៅក្រាមសថ្លាចំនួន ០១ កញ្ចប់ ទម្ងន់ ០,៣៦ ក្រាម ជាប្រភេទមេតំហ្វេតាមីន ចំណុចនេះបញ្ជាក់ពីពិរុទ្ធភាពរបស់ជនជាប់ចោទ។

៧.មានភស្តុងតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ចំរើន ភេទប្រុស អាយុ ១៧ឆ្នាំ ពីបទ៖ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិធម្មត្រ័យ ឃុំផ្សារដែក ស្រុកពញាឮ ខេត្តកណ្តាល កាលពីថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២១ ដែលត្រូវផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ ៤ **នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន**។

៨.អំពើជនជាប់ចោទឈ្មោះ [redacted] ចំរើន **ហៅតុង** បានប្រព្រឹត្តធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់របៀបរាបរយសាធារណៈ និងសន្តិសុខសង្គម ព្រមទាំងធ្វើឱ្យប៉ះពាល់ដល់សុខភាពអ្នកដទៃ តែជនជាប់ចោទជាអនីតិជនដូច្នេះទណ្ឌកម្ម ដែលត្រូវអនុវត្តលើជនជាប់ចោទ តុលាការនឹងពិចារណា។

៩.វត្ថុចាប់យកតាមកំណត់ទទួលវត្ថុតាងរបស់អយ្យការអមសាលាដំបូងខេត្តកណ្តាល ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២១ មាន៖ ថ្នាំញៀនចំនួន ០១កញ្ចប់ ទំងន់០,៣៦ ក្រាម ជាវត្ថុខុសច្បាប់ គប្បីរឹបអូស។ រីឯទូរស័ព្ទចំនួន ០២គ្រឿង មានម៉ាកoppo បែកអេក្រង់ចំនួន ០១ និងNokia ចុចពិល ចំនួន ០១ , ម៉ូតូចំនួន ០១គ្រឿងម៉ាក Honda C125 ពណ៌ខ្មៅ ស្លាកលេខភ្នំពេញ 1Q-1804 ជាមធ្យោបាយទំនាក់ទំនងក្នុងការប្រព្រឹត្តិបទល្មើស គប្បីរឹបអូស។

## ហេតុដូច្នេះសម្រេច

១/-ផ្តន្ទាទោសលើឈ្មោះ [redacted] ចំរើន ហៅ តុង ភេទប្រុស អាយុ ១៧ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ១៨ (ដប់ប្រាំបី)ខែ ពីបទ៖ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិធម្មត្រ័យ ឃុំផ្សារដែក ស្រុក



Scanned with CamScanner

ពញាឮ ខេត្តកណ្តាល កាលពីថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ។

២/-រឹបអូសវត្ថុតាងចាប់យកតាមកំណត់ហេតុទទួលវត្ថុតាងរបស់អយ្យការអមសាលាដំបូងខេត្តកណ្តាល ចុះថ្ងៃទី០៩ខែមីនាឆ្នាំ២០២១ មាន៖ ថ្នាំញៀនចំនួន ០១កញ្ចប់ទំងន់០,៣៦ក្រាម ,ទូរស័ព្ទចំនួន២គ្រឿង មានម៉ាក oppoបែកអេក្រង់ចំនួន០១ និងNokia ចុចពិល ចំនួន០១ និងម៉ូតូ០១គ្រឿងម៉ាក Honda C125 ពណ៌ខ្មៅ ស្លាកលេខភ្នំពេញ1Q-1804។

សាលក្រមនេះជំនុំជម្រះ និងប្រកាសជាអសាធារណៈនៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទ ,មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ រក្សាសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|---|

ហត្ថលេខា និងត្រា[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃពុធ ០២ រោច ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ខេត្តកណ្តាល ,ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២១

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានក្រុមប្រឹក្សា

[redacted]



Scanned with CamScanner